ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# តាកិះខ្លាស្ទុះ
# រយៈពេល ៣ ឆ្នាំ ( ២០១៨ - ២០២០ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | តាកិះខ្លាស្ទុះ |
| ភូមិ | ៖ | កំពង់ព្នៅ |
| ឃុំ | ៖ | កោះខ្ញែរ |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# តាកិះខ្លាស្ទុះ
## រយៈពេល ៣ ឆ្នាំ (២០១៨ - ២០២០)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | តាកិះខ្លាស្ទុះ |
| ភូមិ | ៖ | កំពង់ព្នៅ |
| ឃុំ | ៖ | កោះខ្ញែរ |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

## មាតិកា

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


១-ស្ថានភាពទូទៅ............................................................................................................៣

២-អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម............................................................................៤

ក- ប្រជាសាស្ត្រ.............................................................................................................៤

ខ-មុខរបរ.....................................................................................................................៤

៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍..................................៥

ក-ទីតាំង.......................................................................................................................៥

ខ-ដែននេសាទ...............................................................................................................៥

គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស...........................................................................៥

ឃ-ធនធានជលផល........................................................................................................៥

៤-ការធ្វើនេសាទ..............................................................................................................៦

ក-អ្នកនេសាទ...............................................................................................................៦

ខ-ឧបករណ៍នេសាទ.......................................................................................................៦

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ.......................................................................៦

៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ.............................................................................៧

ក-ទស្សនវិស័យ...........................................................................................................៧

ខ-គោលបំណង............................................................................................................៧

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.................................................................៨

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ.......................................................................៨

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍.................................................................៩

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ.........................................................១០

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត.............................................................១១

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ............................................................១២

គ៦-ផែនការផ្សព្វផ្សាយ...............................................................................................១៣

គ៧-ផែនការបណ្តុះបណ្តាល...........................................................................................១៤

គ៨-ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍...................................................................១៥

គ៩-ផែនការកែលម្អដែននេសាទ.....................................................................................១៥

គ១០-ផែនការអភិវឌ្ឍវារីវប្បកម្ម.....................................................................................១៦

គ១១-ផែនការមុខរបរចិញ្ចឹមជីវិត....................................................................................១៦

ឃ.ផែនការយុទ្ធសាស្ត្រ.................................................................................................១៧

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ...................................១៨

-តារាងកម្មវិធីការងារ..................................................................................................១៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទតាកិៈខ្លាស្ទុះ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ ដោយអង្គការ CAA/Oxfam Australia បន្ទាប់មកអង្គការ WWF បានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទលើកទី១នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ និងបានបន្តកិច្ចព្រមព្រៀងលើទី២នៅថ្ងៃទី២៧ខែកញ្ញា ឆ្នាំ២០១៦។

សហគមន៍នេសាទតាកិៈខ្លាស្ទុះ មានទីតាំងស្ថិតនៅក្នុងភូមិកំពង់ព្នៅ ឃុំកោះខ្ញែរ ស្រុកសំបូរ ខេត្តក្រចេះ ដែលមានសមាជិកសរុបចំនួន ១២៥ នាក់ ស្រីចំនួន ៥០ នាក់ និងមានគណៈកម្មការចំនួន ០៩ នាក់ ស្រីចំនួន ០១ នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ១០៥ គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន ៖

**១- អង្គការ** CAA/Oxfam Australia

- បានបង្កើតកន្លែងអភិរក្សសហគមន៍នេសាទ និងដាក់ស្លាកសញ្ញាចំនួន ០៥ ស្លាក
- បានបង្កើតក្រុមល្បាតសហគមន៍នេសាទ
- ធនាគារស្រូវ ធនាគារក្របី ក្រុមសន្សំប្រាក់
- កសិកម្មចម្រុះ ចិញ្ចឹមសត្វ ដាំបន្លែ ពេទ្យសត្វភូមិ គណៈកម្មការគ្រោះមហន្តរាយភូមិ
- សាងសង់សាលារៀន ផ្ទះគ្រូ
- គម្រោងអនាម័យទឹកស្អាត បង្គន់ អនាម័យចម្រុះ

**២- រដ្ឋបាលជលផល**

- ផ្តល់កាណូតល្បាតចំនួន ០១ គ្រឿង
- ស្លាកសញ្ញាលើក្បូនឬស្សីចំនួន ០៥ ស្លាក

**៣- អង្គការ** CRDT

- ជួយការងារចិញ្ចឹមមាន់

**៤- អង្គការ** WWF

- ជួយរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ
- បានជួយរៀបចំឯកសារ ដើម្បីចុះបញ្ជីសហគមន៍នេសាទជាផ្លូវការ
- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ផែនទីសហគមន៍នេសាទ ដោយមាននិយាមការច្បាស់លាស់
- រៀបចំឯកសារចុះកិច្ចព្រមព្រៀង ផែនការគ្រប់គ្រងសហគមន៍នេសាទដែលទទួលស្គាល់ដោយថ្នាក់ជាតិ
- បានឧបត្ថមទូកកាណូតមួយគ្រឿង អាវពោងចំនួន១០ អាវភ្លៀងចំនួន៥ និងពិលបំភ្លឺពេលយប់ចំនួន៥
- បានរៀបចំក្រុមល្បាត និងផែនការចុះល្បាតប្រចាំខែ។

- បានធ្វើបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍ចំនួន ៤ កន្លែង
- បានធ្វើក្បួនស្លាកសញ្ញាបណ្តែតទឹកសម្គាល់កន្លែងអភិរក្សចំនួន២។

នៅមុនពេលបង្កើតសហគមន៍នេសាទ តែងតែមានបទល្មើសនេសាទកើតមាននៅក្នុងសហគមន៍នេសាទ និងបណ្តាលឱ្យធនធានជលផលមានការថយចុះជាលំដាប់។ ប៉ុន្តែបន្ទាប់ពីបានបង្កើតសហគមន៍មកគណៈកម្មការសហគមន៍បានសហការជាមួយប៉ូលីសប៉ុស្តិ៍ អាជ្ញាធរភូមិ ឃុំ ស្រុក ជលផល និងឆ្មាំទន្លេចុះល្បាតនិង បង្ក្រាបបទល្មើសធ្វើឱ្យបទល្មើសជលផលមានការថយចុះ និងធនធានជលផល និងផ្សោតមានការកើនឡើងវិញ។

ទន្ទឹមនឹងនេះ ក៏នៅមានបទល្មើសនេសាទពីអ្នកខាងក្រៅសហគមន៍នេសាទលួចធ្វើនេសាទ នៅកន្លែងអភិរក្សជាពិសេសនៅពេលយប់។ ដោយសហគមន៍នេសាទមានការខ្វះខាតប្រេង សម្រាប់ចាក់កាណូតចុះយាមល្បាតឱ្យបានទៀងទាត់ ខ្វះទីស្នាក់ការសម្រាប់បំពេញការងារ ខ្វះសំភារៈសម្រាប់ចុះល្បាត។ ម៉្យាងវិញទៀត គណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគមន៍នេសាទ ហើយសមាជិកសហគមន៍នេសាទ ក៏នៅពុំទាន់មានការយល់ដឹង និងចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំផងដែរ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ៥០០ នាក់ ប្រុសចំនួន ២៧០ នាក់ ស្រី ២៣០ នាក់ ក្នុងនោះជនជាតិព្នងចំនួន ៨០% ជនជាតិខ្មែរចំនួន ២០%

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១៤ នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ០៧ នាក់ ស្រី ០៣ នាក់ និងប្រុស ០៤ នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ០៩ នាក់ ស្រី ០៥ នាក់ និងប្រុស ០៤ នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ស្រី ០២ នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ០៦ នាក់ ស្រី ០៤ នាក់ ប្រុស ០២ នាក់

- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ៩៥% ក្រៅពីនេះមានអ្នកកាន់សាសនាកាតូលិកចំនួន ០៥%

-ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៤០ នាក់ ស្រី ២៣ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ៧៧ នាក់ ស្រី ៣៣ នាក់ មធ្យមសិក្សា ១៣ នាក់ ស្រី ០៥ នាក់ និងកំរិតថ្នាក់ឧត្តមសិក្សា ០០ នាក់ ស្រី ០០ នាក់។

### ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

-ធ្វើស្រែវស្សាចំនួន ៧០ គ្រួសារ ទំហំ ១១៣ ហិកតា (១០០%) និងធ្វើស្រូវស្រាលចំនួន(៤៥%) បន្ទាប់ពីធ្វើស្រែវស្សា

-ធ្វើនេសាទជាលក្ខណៈគ្រួសារ ចំនួន ១១២ គ្រួសារ

-ដាំបន្លែចំនួន ៥ គ្រួសារ ទំហំ ៥០ អារ

-ដាំពោតចំនួន ១៦ គ្រួសារ ទំហំ ០៦ ហិកតា

-ធ្វើកម្មករស៊ីឈ្នួលលក់កម្លាំងពលកម្មដាំដើមចេក ត្របែក ក្រូច ដូងប្រេង ដំឡូងមី តាង៉ែន រោងចក្រស្ករអំពៅ បន្ទាប់ពីធ្វើស្រែរួចចំនួន៥០%

-ធ្វើជាងផ្ទះចំនួន ០០ គ្រួសារ

-សិប្បកម្មចំនួន ០០ គ្រួសារ

-លក់ដូរចំនួន ០៤ គ្រួសារ។

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍**

**ក-ទីតាំង**

កន្លែងនេសាទសហគមន៍ តាកិះខ្លាស្នុះ ស្ថិតនៅតាមដងទន្លេមេគង្គលើ មានទំហំ ៤៦០,៥២ ហិកតា និងមាននិយាមការដូចមានចែងនៅក្នុកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

-ខាងជើងទល់នឹងភូមិអូរកក់

-ខាងត្បូងទល់នឹងភូមិកោះច្បារ

-ខាងកើតទល់នឹងភូមិកំពង់ព្នៅ

-ខាងលិចទល់នឹងភូមិកោះរងាវ ។

**ខ-ដែននេសាទ**

កន្លែងនេសាទសហគមន៍តាកិះខ្លាស្នុះ ស្ថិតនៅតាមដងទន្លេមេគង្គដែលមានអន្លង់ កោះ និងព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ និងនៅតាមកោះ។

**គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស**

-អន្លង់អភិរក្សតាកិះ ទំហំ ១១,៦៨ ហិកតា។

**ឃ-ធនធានជលផល**

<u>ប្រភេទត្រី</u> ៖

ត្រីរៀល ត្រីក្អែក ត្រីក្លាំងហាយ ត្រីក្រឆី ត្រីកែស ត្រីប្រា ត្រីក្តី ត្រីក្រាយ ត្រីស្លាត ត្រីឆ្កោក ត្រីកំបុតច្រមុះ ត្របបែល ត្រីខ្យា ត្រីឆ្លាំង ត្រីទ្រនេល ត្រីកញ្ចុះ ត្រីក្អុក ត្រីឈ្វាត ត្រីពោរ ត្រីកែ ត្រីរ៉ស់ ត្រីអំពូង ត្រីស្នក់ ត្រីសណ្តាយ ត្រីប្រម៉ា ត្រីខ្លា ត្រីរមាស ត្រីដំរី ត្រីខ្មាន់ ត្រីព្រលូង ត្រីប៉ាវ៉ា ត្រីឆ្ពិន ត្រីពុកមាត់ឆ្មា ត្រីកន្ទុយស្មើ ត្រីចង្អែង ត្រីកាហែ ត្រីថ្កុរ ត្រីកញ្ជ្រូក ត្រីស្លឹកឬស្សី ត្រីអាចម៌កុក ត្រីចង្វា ត្រីខ្ទីង ត្រីឆ្លូញ ត្រីផ្ទោង ត្រីត្រសក់ ត្រីគល់រាំង ត្រីសារិកាកែវ ត្រីគ្រំ ត្រីឬសចេក ត្រីក្អិត ត្រីព្រួល ត្រីក្រុស ត្រីដំឡូង ត្រីកញ្ជនជ័យ ត្រីដងទែង ត្រីអណ្តែង ត្រីអាចម៌ស្វា ត្រីរនោងរវីង ត្រីកំពត ត្រីកំភ្លាវ ត្រីតាអោន ត្រីកំភ្លាញ ត្រីក្រាញ់ ត្រីខ្សាន ត្រីរាហ៊ូ ត្រីកន្ទ្រងប្រេង។

<u>ប្រភេទវារីសត្វ</u> ៖

កន្ធាយ ល្មិច ពស់ទឹក ពស់ចាន់ល្មម ពស់ត្រី កង្កែប អណ្តើក ។

ប្រភេទព្រៃលិចទឹក ៖

ដើមរៃ ដើមអណ្តែង ដើមត្រស់ ដើមរាំង ដើមអញ្ចែង ដើមអញ្ចៃ ដើមឃ្លា ដើមស្រូល ដើមក្របៅ ដើមតាលា ដើមបបោះ ដើមត្រែង ដើមភ្នំភ្លែង ដើមឃ្លេ ដើមបន្លាយួន ដើមល្វា ដើមកញ្ជ្រឹង ដើមក្តុល ដើមក្រជិត ដើមអណ្តាតត្រកួត ដើមផ្តៅ ដើមដំបង ដើមព្រីង ដើមខ្ទឹមទឹក ។

## ៤-ការធ្វើនេសាទ

### ក-អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍ ចំនួន ១១៥ នាក់ ស្រី ៣៥ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ០០ នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ១២ នាក់ ស្រី ៥ នាក់។

### ខ.ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សន្ទូចរនង | សាង(១០០ផ្លែ) | ៣០ | ផ្លែលេខ ១២ | មករា ដល់ ធ្នូ |
| សំណាញ់ | វង់ | ៥០ | ប្រវែង ៥ ម ក្រឡា ០,០២ ម | មករា ដល់ មិថុនា |
| មង | ត្បូង (៤០ម៉ែត្រ) | ៤០ | ០,០៤ ម- ០,០៥ ម | មករា ដល់ មិថុនា |
| ចាន់ | ចាន់ | ៦០ | មុខ ០,៣ ម កម្ពស់ ០,៦ ម | មិថុនា ដល់ ធ្នូ |
| លប | លប | ៥ | មុខ ១,៥ ម បណ្តោយ ១,២ ម | មិថុនា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៣ ទូក | ១០០ - ៥០០ គីឡូក្រាម | |
| ទូកមានម៉ាស៊ីន | ៤៥ គ្រឿង | ១០០- ៥០០ គីឡូក្រាម | ៥ សេះ - ១៣ សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| មងរៃ | ត្បូង (៤០ម) | ៤០ | ០,០៧ ម- ០,០៨ ម | មករា ដល់ មិថុនា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២០ គ្រឿង | ៨០០ គីឡូក្រាម | ១៣ សេះ |

### គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៩០ គីឡូក្រាម | ៤០ គីឡូក្រាម | ១៣០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

## ក-ទស្សនៈវិស័យ

សហគមន៍នេសាទ តាកិះខ្លាស្ទុះ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ខ-គោលបំណង

-ចូលរួមគ្រប់គ្រងកន្លែងនេសាទសហគមន៍តាកិះខ្លាស្ទុះ

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

## គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

គោលបំណង ៖ - ដើម្បីកំណត់ចំនួនឧបករណ៍នេសាទក្នុងសហគមន៍ឱ្យបានសមស្រប ជៀសវាងការធ្វើនេសាទហួសកម្រិតផលស្តុក

- ដើម្បីឱ្យសមាជិកសហគមន៍នេសាទ និងអ្នកនេសាទមកពីក្រៅសហគមន៍ធ្វើនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ទីតាំង និងពេលវេលានេសាទ។

ផលរំពឹងទុក ៖ - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍

- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | សកម្មភាព | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់<br>១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទ ឧបករណ៍នេសាទ<br>១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | មករា ដល់ ធ្នូ | សន្ទូចរនង | ផ្លែលេខ ១២ | ៣០ សាង | ១សាង(១០០ផ្លែ) |
| | | មករាដល់មិថុនា | សំណាញ់ | ប្រវែង ៥ ម ក្រឡា ០,០២ ម | ៥០ វង់ | |
| | | | មង | ០,០៤ ម- ០,០៥ ម | ៤០ ត្បូង | ត្បូង (៤០ម៉ែត្រ) |
| | | មិថុនា ដល់ ធ្នូ | ចាន់ | មុខ ០,៣ ម កម្ពស់ ០,៦ ម | ៣០ ចាន់ | |
| | | | លប | មុខ ១,៥ ម បណ្តោយ ១,២ ម | ២០ លប | |

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍

គោលបំណង ៖ - ដើម្បីបង្ហាញអ្នកនេសាទក្នុងសហគមន៍ និងក្រៅសហគមន៍ឱ្យបានដឹងពីទីតាំងកន្លែងអភិរក្សត្រីមេពូជ និងអភិរក្សសត្វផ្សោត

- ដើម្បីការពារត្រីមេពូជ និងសត្វផ្សោតនៅក្នុងសហគមន៍។

ផលរំពឹងទុក ៖ - ត្រីមេពូជ និងសត្វផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍

- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។

ផែនការការពារកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះដែន នេសាទ | ទំហំ (ហ.ត) | សកម្មភាព | គម្រោងថវិកា (ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សតាកិៈ | ១១,៦៨ | ២.១-ដាក់ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | ៤៥០ | ០១.០៦.២០១៨ | ៣០.០៧.២០២០ | ដាក់រាល់ឆ្នាំ |
| | | ២.២-ដាក់បង្គោលដែកព្រំប្រទល់ដែលមានស្លាកសម្គាលអន្លង់អភិរក្សជាមួយទង់ជាតិចំនួន៤ | ៦០០ | ០១.០១.២០១៨ | ៣០.០៤.២០២០ | |

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ

គោលបំណង ៖-ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទឧបករណ៍ សំភារៈគ្រប់គ្រាន់ក្នុងការចុះល្បាត និងទប់ស្កាត់បទល្មើសជលផលគ្រប់ប្រភេទ

- ដើម្បីឱ្យសហគមន៍នេសាទមានទីស្នាក់ការដើម្បីធ្វើការងាររដ្ឋបាល ប្រជុំការងារ ការទំនាក់ទំនង និងរក្សាទុកសំភារៈ និងឯកសារផ្សេងៗ ។

ផលរំពឹងទុក ៖- គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាពខ្ពស់

- សហគមន៍នេសាទមានស្នាក់ការសម្រាប់ទំនាក់ទំនងការងារ និងប្រចាំការ។

ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសំភារៈ | ចំនួន | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | អាវពោង | ១០ អាវ | ១,៥០០ | ០១.០៦.២០១៨ | ៣០.០៦.២០១៨ | |
| | អាវភ្លៀង | ២២ អាវ | | | | |
| | ភ្លើងហ្វាដាក់តាមកាណូត | ២ | | | | |
| | វិទ្យុទាក់ទង | ៣ | | | | |
| | អាគុយ ៧០ អំពែរ | ១ | | | | |
| | ឯកសណ្ឋាន និងមួកសម្រាប់ល្បាត | ២២ | | | | |
| | ម៉ាស៊ីនថត | ១ | | | | |
| | អង្រឹង | ១០ | | | | |
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | ទីស្នាក់ការទំហំ ៤មX៦ម | ១ | ២.០០០ | ០១.០៣.២០១៨ | ៣០.១២.២០២០ | |
| ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | ទូកទំហំ ៩ ម X ០,៨ ម | ១ | ១,២០០ | ០១.០៦.២០១៨ | ៣០.០៦.២០២០ | |

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត

គោលបំណង ៖ - ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទ ប្រជុំបូកសរុបលទ្ធផលដែលបានអនុវត្តន៍ លើកបញ្ហាផ្សេងដែលបានជួបប្រទះ លើកផែនការអនុវត្តន៍បន្ត

- ធ្វើរបាយការណ៍ពីលទ្ធផលការងារ ការលំបាក ការងាយស្រួល ទៅអាជ្ញាធរឃុំ ស្រុក ខណ្ឌរដ្ឋបាលជលផលដើម្បីជួយដោះស្រាយ ។

ផលរំពឹងទុក ៖ - សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព

- បញ្ហាលំបាកផ្សេងៗដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្តន៍ទៅថ្ងៃមុខបន្ត ។

ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | អ្នកចូលរួម | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍; - ឆ្នាំទន្លេ | ២០/ខែ<br>=២០X១២=២៤០<br>៣ឆ្នាំ=៧២០ | ២៤.០៦.២០១៨ | ២៤.១២.២០២០ | ប្រជុំរៀងរាល់ខែ រយៈពេល ៣ ឆ្នាំ |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍; - ឆ្នាំទន្លេ<br>- សមាជិកសហគមន៍<br>-អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋបាលជលផល | ៤០០/ឆ្នាំ X ៣ = ១២០០ | ១២.១២.២០១៨ | ១២.១២.២០២០ | មួយឆ្នាំម្តង រយៈពេល ៣ ឆ្នាំ |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍; - ឆ្នាំទន្លេ<br>- សមាជិកសហគមន៍<br>-អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋបាលជលផល | ៣០០/ឆ្នាំ | ២៦.១២.២០១៨ | ៣០.១២.២០២០ | ៣ឆ្នាំម្តង |

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គោលបំណង ៖ - ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព
- សហគមន៍នេសាទមានមធ្យោបាយសម្រាប់ទប់ស្កាត់បទល្មើស។

ផលរំពឹងទុក ៖ - សហគមន៍នេសាទមានការយាមល្បាតទៀងទាត់
- បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ។

ផែនការចុះទប់ស្កាត់បទល្មើសនេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសំភារៈ | គម្រោងថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៥.១-ចុះល្បាតចំនួន ៦ដង ក្នុង១ ខែនៅរដូវប្រាំង (១ដង/៥លីត្រ X ៦ដង =៣០ X៦ខែ = ១៨០លីត្រ) | - ប្រេងសាំងចំនួន ១៨០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៦ លីត្រ | ៥៤០០ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្ត<br>- ឆ្មាំទន្លេ | ០១.០៦.២០១៨ | ៣០.០៦.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |
| ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែ នៅរដូវវស្សា (៥ដង/៥លីត្រ X ៥ដង =២៥ X៦ខែ = ១៥០លីត្រ) | - ប្រេងសាំងចំនួន ១៥០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៦ លីត្រ | ៤១៤០ | | ០១.០៧.២០១៨ | ៣០.០៧.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |

គ៦-ផែនការផ្សព្វផ្សាយ

គោលបំណង ៖ ដើម្បីឱ្យសមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងពីឯកសារផ្សេងៗ របស់សហគមន៍ និង ប្រកាស អនុក្រឹត្យ និងច្បាប់ផ្សេងដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

ផលរំពឹងទុក ៖ សមាជិកសហគមន៍នេសាទ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានមានការយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព។

ផែនការផ្សព្វផ្សាយច្បាប់ជលផល ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | -ឯកសារផ្សព្វផ្សាយ<br>-គ្រូបង្គោល | ២០០ x៣ = ៦០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល សមាជិកសហគមន៍នេសាទ | ០១.០៦.២០១៨ | ០១.០៦.២០២០ | |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀង ប្រកាសស្តីពីការចុះបញ្ជីសហគមន៍នេសាទនិងផែនទីកន្លែងនេសាទសហគមន៍ | | ២០០ x៣ = ៦០០ | | ០១.០៦.២០១៨ | ០១.០៦.២០២០ | |
| ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ២០០ x៣ = ៦០០ | | ០១.០៦.២០១៨ | ០១.០៦.២០២០ | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ២០០ x៣ = ៦០០ | | ០១.០៦.២០១៨ | ៣០.០៦.២០២០ | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោត និងបរិស្ថាន | | ២០០ x៣ = ៦០០ | | ០១.០៦.២០១៨ | ៣០.០៦.២០២០ | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ២០០ x៣ = ៦០០ | | ០១.០៦.២០១៨ | ៣០.០៦.២០២០ | |

គ៧-ផែនការបណ្តុះបណ្តាល

គោលបំណង ៖ ផ្តល់ចំណេះដឹងពីការងាររដ្ឋបាល ការងារធ្វើផែនការ ការងារដឹកនាំ និងនីតិវិធីកសាងឯកសារនានាដល់គណៈកម្មការសហគមន៍នេសាទ។

លទ្ធផលរំពឹងទុក៖ គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំ ការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។

ផែនការបណ្តុះបណ្តាលជូនគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | -ឯកសារបណ្តុះបណ្តាល<br>-គ្រូបណ្តុះបណ្តាល | ៣៥០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ក្រុមល្បាត | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០ | | ០១.០១.២០១៨ | ០១.០១.២០២០ | |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០ | | ០១.០១.២០១៨ | ០១.០១.២០២០ | |
| ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ៣៥០ | | ០១.១២.២០១៨ | ០១.១២.២០២០ | |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសនេសាទបឋម | | ៣៥០ | | ០១.១២.២០១៨ | ០១.១២.២០២០ | |

គ៨-ផែនការចំណូលថវិកា

គោលបំណង ៖ ដើម្បីប្រមូលថវិកាពីសមាជិកមកប្រើប្រាស់សម្រាប់ការងារគ្រប់គ្រងសហគមន៍។

លទ្ធផលរំពឹងទុក ៖ សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។

ផែនការចំណូលថវិកា ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | ប្រមូលភាគទានពីសមាជិកដែលចូលថ្មី | ០១.០១.២០១៨ | ០១.០១.២០២០ | ១០.០០០ | ១.០០០ រៀល/នាក់ |
| ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | ប្រមូលភាគទានប្រចាំឆ្នាំពីសមាជិក | ០១.០១.២០១៨ | ០១.០១.២០២០ | ១២៥.០០០ | ១.០០០ រៀល/នាក់ រយៈពេល៣ឆ្នាំ |
| ៨.៣- ធ្វើកន្លែងទេសចរណ៍កំសាន្តសម្រាប់រកចំណូលដាក់សហគមន៍ | ប្រជុំនិងរៀបចំកន្លែងទេសចរណ៍កំសាន្ត | ០១.០៣.២០១៨ | ០១.០៣.២០២០ | | កិច្ចសហការសមាជិកសហគមន៍នេសាទ |
| ៨.៤-ធ្វើអួរនេសាទសិប្បកម្មដើម្បីរកចំណូលគាំទ្រសហគមន៍នេសាទ | ដាក់ពាក្យស្នើសុំអួរច្រឡំភក់ អួរស្វាន ធ្វើនេសាទសិប្បកម្មសម្រាប់រកប្រាក់ចំណូលគាំទ្រដំណើរការសហគមន៍នេសាទ | ០១.០៣.២០១៨ | ០១.០៣.២០២០ | | កិច្ចគាំទ្រពីស្ថាប័នពាក់ពន័ |

គ៩-ផែនការកែលម្អដែននេសាទ

សំគាល់ ៖ ដោយកន្លែងនេសាទសហគមន៍ស្ថិតនៅតាមដងទន្លេមេគង្គពុំមានផែនការត្រូវកែលម្អឡើយ ។

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |

គ១០-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

កំណត់សំគាល់ ៖ ទីតាំងសហគមន៍ស្ថិតនៅក្នុងតំបន់ទ្រនាប់នៃដងទន្លេមេគង្គ ក្នុងឃុំកោះខ្ញែរ ដែលកំណត់ដោយអនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ ពុំអនុញ្ញាតឱ្យធ្វើ វារីវប្បកម្មបែ ឬស៊ងក្នុងតំបន់ស្នូលនៅរដូវប្រាំង ម៉្យាងវិញទៀតនៅតំបន់នេះ ជាប្រភេទដីមិនគត់ទឹកនៅរដូវប្រាំង ។

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រី | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| | | | | | |

គ១១-ផែនការមុខរបរចិញ្ចឹមជីវិត

គោលបំណង ៖- ដើម្បីធ្វើឱ្យគណៈកម្មការនិងសមាជិកសហគមន៍នេសាទទទួលបានប្រាក់ចំណូល និងជីវភាពបានប្រសើរឡើងតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួម ដើម្បីឈានដល់ការកាត់បន្ថយភាពក្រីក្រ និងការនេសាទក្នុងតំបន់អភិរក្សសត្វផ្សោត។

លទ្ធផលរំពឹងទុក ៖ គណៈកម្មការសហគមន៍នេសាទនិងសមាជិកមានមុខរបរ ទទួលបានប្រាក់ចំនូល ជីវភាពត្រូវបានប្រសើរឡើង និងការធ្វើនេសាទនៅក្នុងតំបន់ស្នូលជាតំបន់អភិរក្សសត្វផ្សោត ត្រូវបានកាត់បន្ថយ ។

ផែនការបង្កើតមុខរបរចម្រុះ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | -គ្រូបណ្តុះបណ្តាល<br>- ឯកសារបណ្តុះបណ្តាល<br>- ថវិកាទុន | ៤០០០ | គ្រូបណ្តុះបណ្តាល គណៈកម្មការ និង សមាជិកសហគមន៍ ដែលជាក្រុមគោដៅ ពី១៥ទៅ២០នាក់ | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ១៥០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | | ២០០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |

## ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តន៍ផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម :

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការអនុវត្តន៍ផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសម្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តន៍ផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តាកិៈខ្លាស្ទះ រយៈពេល ៣ ឆ្នាំ (២០១៨ ដល់ ២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(ដុល្លា) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍<br>- ការនេសាទនៅកន្លែងអភិរក្សនិងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។ | ៦០០ | អង្គការនានា រដ្ឋបាលជលផលសហគមន៍ | ០១.០១.២០១៨ | ០១.០១.២០២០ | |
| | ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | | | | ០១.០៦.២០១៨ | ០១.០៦.២០២០ | |
| | ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | | | | ០១.០៦.២០១៨ | ០១.០៦.២០២០ | |
| គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ | ២.១-ដាក់ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍<br>- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។ | ១៥០ | អង្គការនានា រដ្ឋបាលជលផលសប្បុរសជន | ០១.០៦.២០១៨ | ០១.១២.២០២០ | រៀងរាល់ឆ្នាំ |
| | ២.១-ដាក់បង្គោលដែកព្រំប្រទល់ដែលមានស្លាកសម្គាល់អន្លង់អភិរក្សជាមួយទង់ជាតិចំនួន៤ | | ៦០០ | | ០១.០២.២០១៨ | ០១.១២.២០២០ | |
| គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ | ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាព<br>- សហគមន៍នេសាទមានស្នាក់ការសម្រាប់ទំនាក់ទំនងការងារនិងប្រចាំការ។ | ១.៥០០ | អង្គការនានា រដ្ឋបាលជលផល | ០១.០៦.២០១៨ | ០១.០៦.២០២០ | |
| | ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | | ២.០០០ | | ០១.០៣.២០១៨ | ០១.០៤.២០២០ | |
| | ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | | ១.២០០ | | ០១.០៥.២០១៨ | ០១.០៥.២០២០ | |
| គ៤-ផែនការប្រជុំគណៈកម្មការ | ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព | ៧២០ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៨ | ០១.១២.២០២០ | ប្រជុំរៀងរាល់ខែ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| និងក្រុមល្បាត | ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | -បញ្ហាលំបាកផ្សេងដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្តន៍ ។ | ៣៦០០ | សហគមន៍ | ១២.១២.២០១៨ | ១២.១២.២០២០ | មួយឆ្នាំម្តង |
| | ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | ៣០០ | | ០១.១២.២០២០ | ៣០.១២.២០២០ | បីឆ្នាំម្តង |
| គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ៥.១-ចុះល្បាតចំនួន ៦ ដង ក្នុង១ខែនៅរដូវប្រាំង( ៦ ខែ ) | -សហគមន៍នេសាទមានការយាមល្បាតទៀងទាត់ | ៥៤០០ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៨ | ៣០.០៦.២០២០ | រាល់ឆ្នាំ (៣ឆ្នាំ) |
| | ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែនៅរដូវវស្សា( ៦ ខែ) | -បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ។ | ៤១៤០ | | ០១.០៦.២០១៨ | ៣០.១២.២០២០ | រាល់ឆ្នាំ (៣ឆ្នាំ) |
| គ៦-ផែនការផ្សព្វផ្សាយ | ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ | សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព។ | ៦០០ | អង្គការនានា រដ្ឋបាលជលផល | ០១.០៣.២០១៨ | ៣០.០៣.២០២០ | រាល់ឆ្នាំ (៣ឆ្នាំ) |
| | ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍និងផែនទីកន្លែងនេសាទសហគមន៍ | | ៦០០ | | ០១.០៣.២០១៨ | ៣០.០៣.២០២០ | |
| | ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ៦០០ | | ០១.០៣.២០១៨ | ៣០.០៣.២០២០ | |
| | ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ៦០០ | | ០១.០៦.២០១៨ | ៣០.០៦.២០២០ | |
| | ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតនិងបរិស្ថាន | | ៦០០ | | ០១.០៦.២០១៨ | ៣០.០៦.២០២០ | |
| | ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ៦០០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |
| គ៧-ផែនការបណ្តុះបណ្តាល | ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជ | ៣៥០ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | លផល។ | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ៣៥០ | | ០១.១២.២០១៨ | ០១.១២.២០២០ | |
| | ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជលផលបឋម | | ៣៥០ | | ០១.១២.២០១៨ | ០១.១២.២០២០ | |
| គ៨-ផែនការចំណូលថវិកា | ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ | ២០ | ថវិកា (សហគមន៍) | ០១.០១.២០១៨ | ០១.០១.២០២០ | |
| | ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | | ២០ | | ០១.០១.២០១៨ | ០១.០១.២០២០ | |
| | ៨.៣- ធ្វើកន្លែងទេសចរណ៍កំសាន្តសម្រាប់រកចំណូលដាក់សហគមន៍ | មានការចូលរួមពីអ្នកពាក់ពន័សហគមន៍នេសាទមានថវិកាអូរច្រឡំភក់និងត្រូវមានការគាំទ្រឲ្យធ្វើនេសាទសិប្បកម្ម | | | ០១.០១.២០១៨ | ០១.១២.២០២០ | |
| | ៨.៤- ធ្វើអូរនេសាទសិប្បកម្មដើម្បីរកចំណូលគាំទ្រសហគមន៍នេសាទ | | | | ០១.១១.២០១៨ | ០១.១១.២០២០ | រៀងរាល់ឆ្នាំ |
| គ១១-ផែនការមុខរបរចិញ្ចឹមជីវិត | ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | សមាជិកសហគមន៍មានជំនាញមានមុខរបរ និងអាចរកប្រាក់ចំណូលបាន | ៦០០ | អង្គការនានា រដ្ឋបាលជលផល សហគមន៍ | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |

# តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | | ២០២០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| **គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | |
| ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | | | | | | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| **គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១-ដាក់ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | → | → | → | → | → | → | | | | | | → | → | → | → | → | → | → | | | | | | → | → | → | → | → | → | → | | | | | | → |
| ២.២-ដាក់បង្គោលដែកព្រំប្រទល់ដែលមានស្លាកសម្គាល់អន្លង់អភិរក្សជាមួយទង់ជាតិចំនួន៤ | | | → | → | | | | | | | | | | → | → | → | | | | | | | | | | | → | → | | | | | | | | |
| **គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| |
|---|
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ |
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ |
| ៣.៣-កាល្ហតម៉ាស៊ីន១៣សេះ |
| **គ៤-ផែនការប្រជុំគណៈ កម្មការ និងក្រុមល្បាត** |
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ |
| ៤.២-រៀបចំមហាសន្និបាតសហ គមន៍នេសាទប្រចាំឆ្នាំ |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ |
| **គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ** |
| ៥.១-ចុះល្បាតចំនួន ១០ ដងក្នុង១ ខែនៅរដូវប្រាំង |
| ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែ នៅរដូវវស្សា |
| **គ៦-ផែនការផ្សព្វផ្សាយ** |
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជី |

| Activity | Period 1 | Period 2 | Period 3 |
| --- | --- | --- | --- |
| សហគមន៍និងផែនទីកន្លែងនេសាទសហគមន៍ | | | |
| ៦.៣-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | → | → | → |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផលនិងប្រកាសពាក់ព័ន្ធ | → | → | → |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វជ្រៅតនិង បរិស្ថាន | → | → | → |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍ | → | → | → |
| **គ៧-ផែនការបណ្តុះ បណ្តាល** | | | |
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុនិងរបាយការណ៍ | → | → | → |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | → | → | → |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | → | → | → |
| ៧.៤-បណ្តុះបណ្តាលការតាមដាននិងវិភាគគុណភាពទឹក | → | → | → |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និង ការកសាងសំណុំរឿងបទល្មើសជលផលបឋម | → | → | → |
| **គ៨-ផែនការចំណូល ថវិកា** | | | |

| | | | |
|---|---|---|---|
| ៨.១-ភាគទានពីសមាជិកសហគមន៍ដែលទើបនឹងចូលថ្មី | → | → | → |
| ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | → | → | → |
| ៨.៣- ធ្វើកន្លែងទេសចរណ៍កំសាន្ត សម្រាប់រកចំណូលដាក់សហគមន៍ | → | → | → |
| ៨.៤- ធ្វើអួរនេសាទសិប្បកម្មដើម្បីរកចំណូលគាំទ្រសហគមន៍នេសាទ | → | → | → |
| **គ១១-ផែនការមុខរបរចិញ្ចឹមជីវិត** | | | |
| ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | → | → | → |
| ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | → | → | → |
| ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | → | → | → |

សូមគោរពជូន
លោកមេឃុំកោះខ្សែរ
" ដើម្បីពិនិត្យនិងសម្រួល"
ភូមិកំពង់ព្នៅ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍
នេសាទតាកិៈខ្លាស្មុះ

លេខ : ០១៧ ជ.កត
បានឃើញនិងជូន
លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ
" ដើម្បីពិនិត្យនិងសម្រួល"
កំពី ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៧
នាយផ្នែករដ្ឋបាលជលផលកំពី

លេខ : ១៣៧/ឃ.ខ.ឆ.
បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកំពី
" ដើម្បីពិនិត្យនិងសម្រួល"
ឃុំកោះខ្សែរ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៧
មេឃុំកោះខ្សែរ

អ៊ុក សាវី

លេខ : ១៩៥ ដស.ក្រច

<u>បានឃើញនិងគោរពជូន</u>

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

" <u>ដើម្បីពិនិត្យនិងសម្រួល</u>"

ក្រចេះ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១៧

**នាយខណ្ឌរដ្ឋបាលជលផលក្រចេះ**

**សៀន គិន**

លេខ : ០៤៥ កសករ-ក្រច

<u>បានឃើញនិងគោរពជូន</u>

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" <u>ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ</u>"

ក្រចេះ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៨

ប្រធាន

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ**

**គួយ-ហួត**

លេខ : ១៣៥៩ ជជ

<u>បានឃើញនិងឯកភាព</u>

រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**